**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៩៣៤ សហវ.ប្រក

**ប្រកាស**

**ស្តីពី**

**ការបង្កើតក្រុមការងាររៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ទៅជាអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ដំឡើងនាយកដ្ឋានសហប្រតិបត្តិការនិងគ្រប់គ្រងបំណុល ទៅជាអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល និងបង្កើតនាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើត ក្រុមការងាររៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដែលសរសេរជាអក្សរកាត់ថា **ក.ម.ព.** ដើម្បីរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ អនុលោមតាមយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ របស់រាជរដ្ឋាភិបាល។

អនុប្រធានប្រចាំការក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទទួលបន្ទុកដឹកនាំនិងសម្របសម្រួល **ក.ម.ព.** ដើម្បីធានាប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពការងារ។

**ប្រការ២.-**

**ក.ម.ព.** មានសមាសភាព ដូចខាងក្រោម÷

| | | |
|---|---|---|
| ១-ឯកឧត្តម **សួន ម៉េងគា** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សហប្រធាន |
| ២-ឯកឧត្តម **ហ៊ែល ចំរើន** | អនុរដ្ឋលេខាធិការ និងជាអនុប្រធានប្រចាំការក្រុមប្រឹក្សានីតិកម្ម | សហប្រធាន |
| ៣-ឯកឧត្តម **ឯក ទីរៈជដ្ឋ** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤-ឯកឧត្តម **នេត មុន្នី** | អគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ | អនុប្រធាន |
| ៥-លោក **ស៊ាង ផល្លា** | ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម | អនុប្រធានប្រចាំការ |
| ៦-ឯកឧត្តម **ឆាយ រតនៈ** | អគ្គាធិការ នៃអគ្គាធិការដ្ឋាន | សមាជិក |
| ៧-លោក **ឌី សុវណ្ណា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ | សមាជិក |
| ៨-លោក **រស់ តីរុណា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ | សមាជិក |
| ៩-លោក **ឯមឃិន ទរ:** | អគ្គនាយករងនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ១០-លោក **អ៊ុង លុយណា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានថវិកា | សមាជិក |
| ១១-លោក **សេង ស្រេង** | អគ្គនាយករងនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ | សមាជិក |
| ១២-លោក **ម៉ៅ បុញ្ញខេត្ត** | ប្រធាននាយកដ្ឋានចំណូលសាធារណៈនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ | សមាជិក |
| ១៣-លោក **ម៉ែន ទុត្ថា** | ប្រធាននាយកដ្ឋានសហគ្រាសសាធារណៈនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ | សមាជិក |
| ១៤-លោក **នួន សំបូរ** | ប្រធាននាយកដ្ឋានចំណូលពីទ្រព្យសម្បត្តិរដ្ឋនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ | សមាជិក |
| ១៥-លោក **ឡុង ជិនរិទ្ធ** | ប្រធាននាយកដ្ឋានលទ្ធកម្មទំនិញនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ | សមាជិក |
| ១៦-លោក **ទូច ស្រេង** | ប្រធាននាយកដ្ឋានអធិការកិច្ចហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ជាតិនៃអគ្គាធិការដ្ឋាន | សមាជិក |
| ១៧-លោក **ភីម្នា សុផុន** | ប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ១៨-លោក **ជ្រុន ផេរ៉ាវ៉ាត** | ប្រធាននាយកដ្ឋានគ្រប់គ្រងអាជីវកម្មភ្នាល់ និង | |

ប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ សមាជិក

១៩- លោក **ឡាយ សុខឃៀង** ប្រធាននាយកដ្ឋានថវិកានីយកម្ម
នៃអគ្គនាយកដ្ឋានថវិកា សមាជិក

២០- លោក **ឈាង ទណ្ឌារិទ្ធ** ប្រធាននាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច
និងសារពើពន្ធ នៃអគ្គនាយកដ្ឋានគោលនយោបាយ
សេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ សមាជិក

២១- លោក **ឆក សុខុម** អនុប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង សមាជិក

២២- លោក **ជា ទណ្ឌារ័ត្ន** អនុប្រធាននាយកដ្ឋានចំណូលចំណាយថវិកា
នៃអគ្គនាយកដ្ឋានរតនាគារជាតិ សមាជិក

២៣- លោក **ជ័យ រិទ្ធី** អនុប្រធាននាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ
នៃអគ្គនាយកដ្ឋានពន្ធដារ សមាជិក

២៤- លោក **ឈុំ ស៊ីនិត** អនុប្រធានលេខាធិការដ្ឋាន នៃអគ្គនាយកដ្ឋាន
ទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ សមាជិក

២៥- កញ្ញា **ឈុន ជាលីន** អនុប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានគោលនយោបាយ
សេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ សមាជិក

២៦- លោក **រស់ សុខណារុណ** អនុប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម សមាជិក

២៧- លោក **ណាន សាមឌី** អនុប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម សមាជិក

២៨- លោក **ផន ចាន់រិទ្ធ** ប្រធានការិយាល័យ នៃអគ្គនាយកដ្ឋាន
ហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ សមាជិក

២៩- លោក **លី ទ៊ុច** មន្ត្រីជំនាញ នៃអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការ
ដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សមាជិក

៣០- លោក **អ៊ិច មករា** មន្ត្រីជំនាញ នៃអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការ
ដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សមាជិក

៣១- កញ្ញា **ឈឿង រចនី** មន្ត្រីនៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម សមាជិក។

**ប្រការ៣._**

**ក.ម.ព.** មានភារកិច្ច ដូចខាងក្រោម÷

- រៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ អនុលោមតាមយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨
- រៀបចំផែនការសកម្មភាព ក្នុងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធអនុលោមតាមយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨

- សិក្សាស្រាវជ្រាវនិងធ្វើទស្សនកិច្ចសិក្សាអំពីឧត្តមានុវត្តន៍ជាតិនិងអន្តរជាតិ ព្រមទាំងកំណត់បញ្ហាប្រឈម ពាក់ព័ន្ធការគ្រប់គ្រងនិងត្រួតពិនិត្យចំណូលមិនមែនសារពើពន្ធ ទាំងក្នុងកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីជាធាតុចូលក្នុងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ
- រៀបចំកិច្ចប្រជុំ និងកិច្ចពិគ្រោះយោបល់នានា លើសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការងាររបស់ខ្លួន ប្រចាំត្រីមាស ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រៀបចំឯកសារជំនួយស្មារតីនិងឯកសារផ្សេងៗទៀត ពាក់ព័ន្ធសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៦

**អ្នកទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**អូន ព័ន្ធមុនីរ័ត្ន**